ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ២៩៧,៥៣ ហិកតា នៅស្រុកត្រាំកក់ ខេត្តតាកែវ ចេញពីដីព្រៃសហគមន៍ស្រុកត្រាំកក់ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៥៨៨ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ០៧៥សណ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.**

ត្រូវបានកាត់ដីសរុបទំហំ ២៩៧,៥៣ ហិកតា ចេញពីដីព្រៃសហគមន៍ស្រុកត្រាំកក់ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ២៧៤,១៣ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ២៣,៤០ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ស្ថិតនៅក្នុងភូមិ ដូចខាងក្រោម៖

- ផ្ទៃដីទំហំ ៩៣,៥៥ហិកតា កាត់ចេញពីដីព្រៃសហគមន៍ស្រុកត្រាំកក់ សម្រាប់ប្រទានកម្មដីទំហំ ៨៨,១២ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៥,៤៣ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិប្រវន័យ
- ផ្ទៃដីទំហំ ៤៨,៦៥ហិកតា កាត់ចេញពីដីព្រៃសហគមន៍ស្រុកត្រាំកក់ សម្រាប់ប្រទានកម្មដីទំហំ ៤៤,៩៩ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៣,៦៦ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងថ្នល់
- ផ្ទៃដីទំហំ ២១,១៩ហិកតា កាត់ចេញពីដីព្រៃសហគមន៍ស្រុកត្រាំកក់ សម្រាប់ប្រទានកម្មដីទំហំ ១៩,៤៦ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ១,៧៣ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងរបើម
- ផ្ទៃដីទំហំ ៥៨,៣៨ហិកតា កាត់ចេញពីដីព្រៃសហគមន៍ស្រុកត្រាំកក់ សម្រាប់ប្រទានកម្មទំហំ ៥៣,៧០ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៤,៦៨ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិប្រជុំ
- ផ្ទៃដីទំហំ ៧៥,៧៦ហិកតា កាត់ចេញពីដីព្រៃសហគមន៍ស្រុកត្រាំកក់ សម្រាប់ប្រទានកម្មទំហំ ៦៧,៨៦ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៧.៩០ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃមោក

តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចក័ណាត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណាគ្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៥៨៨គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ នៅក្នុងភូមិដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១២៣គ្រួសារ នៅភូមិប្រវន័យ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៥គ្រួសារ នៅភូមិត្រពាំងថ្នល់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៧គ្រួសារ នៅភូមិត្រពាំងរបើម
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១២៤គ្រួសារ នៅភូមិប្រជុំ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០៩គ្រួសារ នៅភូមិព្រៃមោក ។

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តតាកែវ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*